# ខ្លឹមសារសង្ខេប ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

(សំណុំរឿង ០០១, C3/9 ចុះថ្ងៃទី ៣១ ខែ កក្កដា ២០០៧)

ពាក្យគន្លឹះ៖ ការឃុំខ្លួនបណ្ដោះអាសន្ន-ភាពចាំបាច់- គោលការណ៍សន្មត់ថាមានសេរីភាព-ការបំពាននីតិវិធី

១. មុននឹងសម្រេចឃុំខ្លួនជនសង្ស័យ នីតិវិធីដេញដោល ត្រូវបានធ្វើឡើង (adversary proceeding)។ ឌុច បានលើកឡើងនូវបញ្ហាចំនួនពីរ៖ ទី១. ការឃុំខ្លួនគាត់មិនចាំបាច់ទេ និង ទី២. សហចៅក្រមស៊ើបអង្កេត ត្រូវទម្លាក់ការចោទប្រឆាំងនឹងគាត់ចោល ដោយសារ ការឃុំខ្លួនគាត់នៅតុលាការយោធា មុននាំយកមកសាលាក្ដីខ្មែរក្រហម (អវតក) ខុសច្បាប់។ នេះជាការបំពាននីតិវិធី (abuse of process) ដែលអាចនាំឲ្យមានការផ្អាកនីតិវិធី (stay of proceeding) ឬ មោឃៈភាពកិច្ចរបស់តុលាការ (annulment) និងជាបញ្ហាទី១ ត្រូវតែដោះស្រាយជាមុន ហើយមានភាពប្រទាក់ក្រឡាគ្នានឹងបញ្ហាឃុំខ្លួន។

២. ពាក់ព័ន្ធនឹងការឃុំខ្លួន ឌុច បានអះអាងជាសំខាន់ថា កន្លងមក គាត់រស់ដោយគ្មានការយាយី ជាយូរមកហើយ មុនត្រូវបានចាប់ខ្លួន។ ដូចនេះការឃុំខ្លួន មិនចាំបាច់ទេ។ ឌុច តាមរយៈមេធាវី បានលើកសំអាងនូវយុត្តិសាស្ត្រមួយចំនួន ដែលបង្ហាញថាតុលាការ នឹងមិនអនុវត្តយុត្តាធិការទេ ប្រសិនបើ ជនសង្ស័យ ត្រូវបានចាប់ខ្លួន ឬឃុំខ្លួនខុសនឹងនីតិវិធីច្បាប់ (កថាខ័ណ្ឌទី១)។

៣. ក្នុងដំណើរការនេះ សហព្រះរាជអាជ្ញា ក៏បានចូលរួមលើកអំណះអំណាងដែរ។ សហចៅក្រមស៊ើបអង្កេត បានពិនិត្យមើល និងពិចារណា នូវអំណះអំណាងរបស់ភាគីទាំងអស់ រួមជាមួយនឹងយុត្តិសាស្ត្រជាតិ អន្តរជាតិ ដូចជា ប្រទេស អាមេរិក អ៊ីស្រាអ៊ែល តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ពាក់ព័ន្ធនឹងការបំពាននីតិវិធី ព្រមទាំងក្របខ័ណ្ឌច្បាប់ទាក់ទងនឹងការឃុំខ្លួន។ ទាំងអស់នេះជាវិធានដែលអនុវត្ត និងជាផ្នែកមួយនៃសំអាងហេតុ ដើម្បីសម្រេចថា តើនីតិវិធីត្រូវដើរទៅមុខ ហើយចាំបាច់ទេ ក្នុងការឃុំខ្លួន ឌុច។ ជាទូទៅ ការចាប់ខ្លួន និងការងារចោទប្រកាន់ដោយតុលាការ ជាការងារពីរដាច់ដោយឡែកពីគ្នា។ ក្នុងន័យថា ការចាប់ខ្លួនខុសច្បាប់ មិនរាំងដល់ការអនុវត្តសមត្ថកិច្ចរបស់តុលាការទេ។ ទោះបីជាយ៉ាងនេះក្ដី មានករណីលើកលែង ដែលទង្វើមុន ដូចជាការចាប់ខ្លួន ឬឃុំខ្លួន ខុសច្បាប់ ឬសិទ្ធិមនុស្សធ្ងន់ធ្ងរពេក ដែលតុលាការ មិនអាចមើលរំលងបាន ហើយត្រូវអន្តរាគមន៍ ក្នុងហេតុផលមួយកុំឲ្យគេចោទថា តុលាការចូលរួមបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ។ សិទ្ធិនោះ ដូចជាសិទ្ធិរួចផុតអំពើទារុណកម្ម។ តុលាការក៏ត្រូវអន្តរាគមន៍ផងដែរ សូម្បីការបំពាននោះ មិនពាក់ព័ន្ធនឹងអាជ្ញាធររបស់ខ្លួន (ដូចជាកថាខ័ណ្ឌទី១៣-១៦)។

៤. ផ្អែកលើវិធានខាងលើ និងដោយរកឃើញថា សិទ្ធិរបស់ឌុចមិនត្រូវបានបំពានធ្ងន់ធ្ងរ សហចៅក្រមស៊ើបអង្កេត សម្រេចថា មិនមានអ្វីរាំង ការចោទប្រកាន់ឌុចទេ ហើយបន្តទៅពិនិត្យមើល ថាការឃុំខ្លួនឌុច ចាំបាច់ដែរឬទេ? តាមច្បាប់ ដើម្បីឃុំខ្លួនបាន ជនសង្ស័យបានប្រព្រឹត្តបទល្មើស និងឃុំខ្លួន ជាការចាំបាច់។ សហចៅក្រមស៊ើបអង្កេតមាន ភស្ដុតាងរឹងមាំ (well-founded) ថាឌុច បានប្រព្រឹត្តបទល្មើស។ ក្រោយ

ពេល ឱុច ត្រូវបាននាំខ្លួនមក អវតក សាធារណៈជនជាច្រើន បានចាប់អារម្មណ៍ ហើយដែលការដាក់ឱុចនៅក្រៅឃុំ អាចនាំឲ្យគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់គាត់។ ឱុច អាចប្រឈមមុខនឹងទោសធ្ងន់ដែលនេះ អាចនាំឲ្យគាត់គេចខ្លួន មិនត្រឡប់មកចូលរួមក្នុងដំណើរការនីតិវិធីវិញ។ ជាចុងក្រោយ ជម្រើសតម្កល់ប្រាក់ធានានៅក្រៅឃុំ ក៏មិនអាចទៅរួចដែរ ទើប សហចៅក្រមស៊ើបអង្កេត សម្រេចថា ការឃុំខ្លួនគឺជាការចាំបាច់។

**<u>កំណត់សំគាល់</u>**៖ **<u>ក</u>**. ការឃុំខ្លួន ប៉ះពាល់ដល់សិទ្ធិសេរីភាពបុគ្គល។ អាស្រ័យហេតុនេះ ដើម្បីឃុំខ្លួន ត្រូវផ្អែកលើមូលដ្ឋានរឹងមាំ ដើម្បីធានាថាឃុំខ្លួនជាការចាំបាច់ លុបលើគោលការណ៍សន្មត់ថាមានសេរីភាព (presumption of liberty)។ **<u>ខ</u>**. ក្នុងករណីនេះ មិនមានការបំពានសិទ្ធិឱុចធ្ងន់ធ្ងរទេ។ ប្រសិនបើមាន អវតក នឹងមិនអាចបន្តនីតិវិធីបានទេ ពីព្រោះ វាអាចនាំឲ្យបំពានសិទ្ធិ និងកាតព្វកិច្ចច្បាប់អន្តរជាតិ ក៏ដូចច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ដែលចែងធានានូវសិទ្ធិសុវត្ថិភាពបុគ្គល។ សេចក្តីសម្រេចនេះ ជាការរំលឹកដល់ អាជ្ញាធរចាប់ខ្លួន ឬឃុំខ្លួន ឲ្យគោរពនូវសេរីភាពបុគ្គល ប្រសិនបើមិនដូចនេះទេ វាអាចនឹងមានហានីភ័យ ថាជនសង្ស័យ អាចនឹងត្រូវបានដោះលែង ដោយសារ ការបំពាននីតិវិធី។ នេះក៏អាចជាមូលហេតុ ដែលនាំឲ្យមេធាវី អាចសុំដោះលែង ជនសង្ស័យ ឲ្យមានសេរីភាពផងដែរ។